**អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក**
អគារ ជីអាយអេ ថៅអឺរ ជាន់ទី៣១ ផ្លូវសុគមង្គល ភូមិ១៤ សង្កាត់
ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទ៖ (855) 86 999 242

AIA.COM.KH

# អត្ថបទសារព័ត៌មាន

## វគ្គបណ្តុះបណ្តាលបាល់ទាត់ AIA-Spurs Elite Football Camp ឆ្នាំនេះ ស្វាគមន៍ កីឡាករបាល់ទាត់វ័យក្មេងក្រុមទី 2 ដែលពោរពេញដោយទេពកោសល្យ

ភ្នំពេញ ថ្ងៃទី 04 ខែសីហា ឆ្នាំ 2023 – ក្រុមហ៊ុន អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក ("អេ អាយ អេ ខេមបូឌា") ផ្តោតសំខាន់លើការបណ្តុះបណ្តាលគំនិត និងកាយសម្បទារបស់យុវជនឲ្យមានសុខភាពល្អ តាមរយៈកីឡា និងបណ្តុះថ្នាលជើងឯកកីឡាបាល់ទាត់ដោយឃើញថា AIA Group បានរៀបចំ និងផ្តល់ឱកាសដល់ក្រុមកីឡាករវ័យក្មេងមួយក្រុមទៀតដែលស្រឡាញ់វិស័យកីឡាបាល់ទាត់ឲ្យចូលរួមវគ្គបណ្តុះបណ្តាលបាល់ទាត់ AIA-Spurs Elite Football Camp ។

វគ្គបណ្តុះបណ្តាលដែលមានរយៈពេល 4 ថ្ងៃនៅកោះសាមុយ ប្រទេសថៃ ស្វាគមន៍យុវជនចំនួន 18 នាក់ដែលត្រូវបានសម្រិតសម្រាំងចេញពីកម្មវិធី "AIA-Spurs បាល់ទាត់ដើម្បីសុខភាពកុមារ" ដែលទទួលបានការសម្របសម្រួល និងបង្ហាត់ដោយផ្ទាល់ពីពីគ្រូបង្វឹក ផ្នែកអភិវឌ្ឍបាល់ទាត់អន្តរជាតិ មកពីក្លឹបបាល់ទាត់ Tottenham Hotspur របស់ក្របខណ្ឌកំពូលប្រទេសអង់គ្លេស ដែលក្លឹបនេះគឺជាដៃគូសកលដ៏សំខាន់របស់ អេ អាយ អេ ។

គ្រូបង្វឹក Jadon Anderson និង Danny Mitchell បានអះអាងបញ្ជាក់ថា កីឡាករវ័យក្មេងរបស់យើងទទួលបាន ចំណេះជំនាញចាំបាច់ ដើម្បីក្លាយជាកីឡាករលំដាប់ពិភពលោក ចែករំលែកការយល់ដឹង បទពិសោធ និងគន្លឹះអភិវឌ្ឍ ដែលនឹងផ្តល់ឲ្យក្រុមកីឡាករ នូវគន្លឹះក្នុងការហ្វឹកហាត់ ប្រសិនបើពួកគេចង់ក្លាយកីឡាករបាល់ទាត់អាជីព។

ជាងនេះទៀតសោធ ក្រុមកីឡាករវ័យក្មេងទាំងនោះ ក៏ទទួលបានចំណេះដឹងដ៏មានសារៈប្រយោជន៍លើ អាហារូបត្ថម្ភ ការគេងគ្រប់គ្រាន់ និងកត្តាចាំបាច់ផ្សេងៗទៀតដើម្បីឈានទៅការរស់នៅឲ្យមានសុខភាពល្អ។ វគ្គបណ្តុះបណ្តាលនេះក៏បានដើរតួនាទីក្នុងការជំរុញទំនុកចិត្ត បណ្តុះភាពអត់ធ្មត់ ការប្តេជ្ញាចិត្ត និងការអភិវឌ្ឍជំនាញទំនាក់ទំនងសង្គមដល់ក្រុមកីឡាករ បន្ថែមទៀតតាមរយៈការផ្តល់ឱកាសឲ្យពួកគាត់ទៅកន្លែងថ្មីៗ និងជួបប្រាស្រ័យទាក់ទងជាមួយមនុស្សកាន់តែច្រើន។

គួរបញ្ជាក់ផងដែរថា ការធ្វើដំណើររបស់ពួកគេទទួលបានការទំនុកបម្រុងដោយ AIA Group និងគាំទ្រដោយ អេ អាយ អេ ខេមបូឌា រួមជាមួយនឹងក្លឹបបាល់ទាត់ Spurs។ កិច្ចសហការនេះមានគោលបំណងជួយ អេ អាយ អេ ខេមបូឌា ដែលជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតឈានមុខគេរបស់ព្រះរាជាណាចក្រកម្ពុជាឲ្យសម្រេចបាននូវ

**អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក**
អគារ ជីអាយអេ ថៅអឺរ ជាន់ទី៣១ ផ្លូវសុភមង្គល ភូមិ១៤ សង្កាត់
ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទ៖ (855) 86 999 242

AIA.COM.KH

# អត្ថបទសារព័ត៌មាន

គោលបំណងរបស់ខ្លួនក្នុងការផ្តល់ជូនប្រជាជនកម្ពុជាទាំងអស់នូវសុខភាព និងជីវិតកាន់តែប្រសើរឡើង។ ភាពជាដៃគូនេះក៏ជួយពង្រឹងជំហររបស់ក្រុមហ៊ុន ក្នុងនាមជាអ្នកគាំទ្រយ៉ាងពេញទំហឹងលើ កីឡាបាល់ទាត់ និងកីឡាផ្សេងៗទៀតដែលជាយានដ្ឋនាំឲ្យប្រជាជនទទួលបាន សុខុមាលភាព និងសុខភាពល្អ។

វគ្គហ្វឹកហាត់ បាល់ទាត់ AIA-SPURS Elite Football Camp លើកនេះជាលើកទី 2 ក្នុងឆ្នាំ 2023 ដែលលើកទីមួយបានប្រព្រឹត្តទៅកាលពីខែ មិថុនា ដែលបានស្វាគមន៍ យុវតីចំនួន 24 នាក់មកពីអង្គការផ្កាយសមុទ្រកម្ពុជានៅលើទឹកដីកោះ សាមុយ  ដែលនេះជាឱកាសមិនអាចបំភ្លេចបានក្នុងមួយជីវិតរបស់ពួកគាត់ ដែលបានធ្វើដំណើរតាមយន្តហោះទៅក្រៅប្រទេស ហើយបានបង្ហាញពីអត្ថប្រយោជន៍ ក្នុងការពង្រឹងការអភិវឌ្ឍ និងជំនាញផ្ទាល់ខ្លួនរបស់ពួកគេ។

លោក Andrew Loh អគ្គនាយកនៃក្រុមហ៊ុន  អេ អាយ អេ ខេមបូឌា មានប្រសាសន៍ថា៖ “យើងជឿថា កីឡាដើរតួនាទីយ៉ាងសំខាន់ សម្រាប់យុវជនកម្ពុជាក្នុងការចាប់ផ្តើមលើវិថីឆ្ពោះទៅរកសុខភាព និងជីវិតកាន់តែប្រសើរ។ ជាក់ស្តែង កម្មវិធីបណ្តុះបណ្តាលបាល់ទាត់ AIA-Spurs Elite Football Camp អនុញ្ញាតឲ្យយើងបណ្តុះថ្នាលកីឡាករដើម្បីក្លាយជាជើងឯកនាពេលអនាគត និងជួយពួកគេឲ្យសម្រេចបាននូវគោលដៅរបស់ពួកគេតាមរយៈការចូលរួមហ្វឹកហាត់បាល់ទាត់ស្តង់ដាអន្តរជាតិកំពូល និងកត្តាពាក់ព័ន្ធផ្សេងទៀតដែលជួយពង្រឹងសុខភាព ផ្លូវចិត្ត និងកាយសម្បទា។”

“អេ អាយ អេ ខេមបូឌា នឹងបន្តរៀបចំគំនិតផ្តួចផ្តើម និងកម្មវិធីបន្ថែមទៀត ដែលជំរុញទឹកចិត្តកុមារឲ្យចាប់យកជីវិតសកម្ម និងមានសុខភាពល្អ ផ្តល់ឲ្យពួកគេនូវបទពិសោធន៍សិក្សាក្នុងបរិយាកាសដ៏រីករាយ និងបន្តពង្រឹងសមត្ថភាពរបស់ពួកគេក្នុងការកសាងអនាគតកាន់តែប្រសើរឡើងសម្រាប់ខ្លួនពួកគេផ្ទាល់ និងសហគមន៍ដែលពួកគេរស់នៅ។”

សម្រាប់ព័ត៌មានបន្ថែមអំពី អេ អាយ អេ ខេមបូឌា  និងកម្មវិធីទាក់ទងនឹងបាល់ទាត់សម្រាប់កុមារនិងយុវជន សូមផ្ញើអ៊ីម៉ែលមកកាន់  kh.marketing@aia.com  ។  សម្រាប់ព័ត៌មានលម្អិតលើដំណោះស្រាយការពារអាយុជីវិត ជំងឺធ្ងន់ធ្ងរ គ្រោះថ្នាក់ចៃដន្យ និងការការពាសុខភាព សូមទាក់ទង AIA Client Care តាមរយៈលេខ 086 999 242 ចូលទៅកាន់ aia.com.kh ឬចូលទៅកាន់គេហទំព័រ www.facebook. com/AIACambodia។

**អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក**
អគារ ជីអាយអេ ថៅអឺរ ជាន់ទី៣១ ផ្លូវសុភមង្គល ភូមិ១៤ សង្កាត់
ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទ៖ (855) 86 999 242

AIA.COM.KH

# អត្ថបទសារព័ត៌មាន

## អំពី អេ អាយ អេ ខេមបូឌា

ក្រុមហ៊ុនធានារ៉ាប់រង អេ អាយ អេ ខេមបូឌា គឺជាបុត្រសម្ព័ន្ធនៃ AIA Group មានក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតនៅទូទាំងតំបន់អាស៊ីដែលស្ថិតក្នុងបញ្ជីឈ្មោះសាធារណៈឯករាជ្យធំជាងគេ។ ក្រុមហ៊ុនមានវត្តមាននៅលើទីផ្សារចំនួន 18 ប្រទេសនៅអាស៊ីប៉ាស៊ីហ្វិក - សាខាគ្រប់គ្រងទាំងស្រុង។

ចាប់តាំងពីបើកដំណើរការនៅកម្ពុជា រាល់សកម្មភាពរបស់ អេ អាយ អេ ខេមបូឌា ធ្វើឡើងស្របតាមគោលបំណងក្នុងការជួយឲ្យប្រជាជនកម្ពុជាឲ្យរស់នៅមានសុខភាព និងជីវិតកាន់តែប្រសើរ។ ចាប់តាំងពីចាប់ផ្តើមអាជីវកម្មក្នុងឆ្នាំ 2017 យើងបានក្លាយជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត និងសុខភាពដំបូងបង្អស់នៅកម្ពុជា ផ្តល់ការការពាររហូតដល់ 26 ស្ថានភាពជំងឺធ្ងន់ធ្ងរ។ ក្នុងនាមជាក្រុមហ៊ុនធានារ៉ាប់រងឈានមុខគេមួយនៅកម្ពុជា អេ អាយ អេ ខេមបូឌា ផ្តល់ជូននូវដំណោះស្រាយជីវិតឈានមុខគេនៅលើទីផ្សារសម្រាប់ប្រជាជនកម្ពុជាគ្រប់មជ្ឈដ្ឋាន រាប់ចាប់ពីគម្រោងធានារ៉ាប់រងសំខាន់ៗដែលបង្កើតឡើងស្របតាមតម្រូវការជាក់លាក់ ដែលរួមមានគម្រោងការពារលើជំងឺធ្ងន់ធ្ងរ គ្រោះថ្នាក់ចៃដន្យ ថ្លៃសម្រួលការសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងជំនួយសង្គ្រោះបន្ទាន់នៅក្រៅប្រទេស។

អេ អាយ អេ ខេមបូឌា ផ្តោតសំខាន់លើការណែនាំ និងជម្រុញឲ្យប្រជាជនក្នុងសង្គមទទួលយកទម្លាប់ល្អៗ ក៏ដូចជាមធ្យោបាយដើម្បីឲ្យពួកគាត់ទទួលបាននូវសុខភាពល្អ តាមរយៈគំនិតផ្តួចផ្តើម រួមមានកិច្ចសហការ ជាមួយក្រសួងកិច្ចការនារី ដើម្បីពង្រឹងលើសមភាពយេនឌ័រនិងសិទ្ធិស្ត្រី ការលើកកម្ពស់ការយល់ដឹងអំពីជំងឺមហារីកសុដន់ តាមរយៈយុទ្ធនាការប្រចាំឆ្នាំ Fit for Hope របស់យើងជាដើម។

យើងក៏ចូលរួមជួយលើកស្ទួយកុមារដែលជួបបញ្ហាជីវភាពរាប់ពាន់នាក់ផងដែរ ដោយតាមរយៈឧបត្ថម្ភដល់លីគបាល់ទាត់ AIA-ISF ដែលជាលីគបាល់ទាត់ថ្នាក់មូលដ្ឋានធំជាងគេនៅកម្ពុជា។ ជាងនេះទៀតសោធ យើងក៏សហការជាមួយក្លឹបTottenham Hotspur ក្នុងក្របខណ្ឌ English Premier League ដែលជាដៃគូសកលនិងជាក្លឹបបាល់ទាត់កំពូលនៅលើពិភពលោក ដើម្បីធានាថាកុមារទាំងនោះទទួលបានការអប់រំដែលពួកគេសមនឹងទទួលបាន។

អេ អាយ អេ ខេមបូឌា គឺជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតកម្ពុជាតែមួយគត់ដែលបានទទួលពានរង្វាន់ "ក្រុមហ៊ុនល្អបំផុតសម្រាប់ការងារនៅអាស៊ី (Best Companies to Work for in Asia)" ពី HR Asia ក្នុងរយៈពេល 3 ឆ្នាំជាប់គ្នា 2020, 2021 និង 2022។ អេ អាយ អេ ខេមបូឌា មានការិយាល័យកណ្តាលនៅទីក្រុងភ្នំពេញ និងបច្ចុប្បន្នបានពង្រីកសាខានៅខេត្តសៀមរាប កំពត កំពង់ចាម និងបាត់ដំបង។

**អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក**
អគារ ជីអាយអេ ថៅអឺរ ជាន់ទី៣១ ផ្លូវសុភមង្គល ភូមិ១៤ សង្កាត់
ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទ៖ (855) 86 999 242

AIA.COM.KH

# អត្ថបទសារព័ត៌មាន

ទំនាក់ទំនងសារព័ត៌មាន

ម៉េង ដាណែត

ប្រធានផ្នែកទំនាក់ទំនងសាធារណៈ

អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក